THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាប្តេជ្ញាផ្តល់នូវបរិយាកាសសិក្សាដែលប្រកបដោយសុវត្ថិភាព និង ការរួមបញ្ចូល ដែលគាំទ្រដល់សុខភាពផ្លូវអារម្មណ៍ និងផ្លូវចិត្ត របស់សិស្សទាំងអស់របស់យើង ដូចបាន រៀបរាប់នៅក្នុង គោលដៅ និងការទប់ស្កាត់ របស់ក្រុមប្រឹក្សាភិបាលនៃក្រសួងអប់រំ ជាផ្នែកមួយនៃការ ប្តេជ្ញាចិត្តនោះ យើងមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសថា ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី១៣ ខែធ្នូ ឆ្នាំ២០២១ តទៅ **សិស្សនឹងអាចជ្រើសរើសជម្រើសភេទថាជាប្រុសផង ឬស្រីផង ឬគ្មានភេទ** បន្ថែមពី លើជម្រើសប្រុស និងស្រី ដែលនឹងបង្ហាញនៅក្នុង Infinite Campus (គេហទំព័រសម្រាប់សិស្ស និង ក្រុមគ្រួសារ) ក្នុង google classroom ឬទាំងពីរ។

ច្បាប់របស់ក្រសួងលេខ 252 បញ្ជាក់ពីសិទ្ធិរបស់សិស្ស ប្តូរភេទ (transgender) និងសិស្សដែលមិន អនុលោមតាមភេទក្នុងការជ្រើសរើស និងកំណត់ថាជាឈ្មោះ និងភេទដែលពួកគេចូលចិត្ត ទោះជាខុស ពីអ្វីដែលបានសរសេរនៅលើសំបុត្រកំណើតក៏ដោយ។ ដើម្បីគាំទ្រច្បាប់នោះ សិស្សអាចទំនាក់ទំនង ចំណូលចិត្តរបស់ពួកគេចំពោះរបៀបដែលបង្ហាញឈ្មោះ និងភេទរបស់ពួកគេទៅកាន់ ការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវ របស់សិស្ស (Office of Student Rights and Responsibilities) ដោយ ប្រើលិខិតដែលបានភ្ជាប់នៅត្រង់នេះ ដោយមិនចាំបាច់ផ្តល់ឯកសារផ្លូវច្បាប់ ឬត្រូវការការយល់ព្រមពី មាតាបិតា ឬអាណាព្យាបាល។ ពួកគេមានជម្រើសពីរ៖

១) **ផ្តល់ ឈ្មោះ និង/ឬ ភេទ ថ្មី នៅក្នុង Google តែប៉ុណ្ណោះ៖** នេះនឹងបង្ហាញតែក្នុងឧបករណ៍ Google តែប៉ុណ្ណោះ ដូចជា Google Classroom, Google Meet ជាដើម។

២) **ផ្តល់ ឈ្មោះ និង/ឬ ភេទ ថ្មី នៅក្នុង SIS (ដែលរួមបញ្ចូលទាំង Google)៖** បន្ថែមពីលើ ឧបករណ៍ Google ទាំងអស់ ព័ត៌មានថ្មីៗដែលបង្ហាញទូទាំងប្រព័ន្ធប្រឈមនឹងសិស្ស និង សាលាផ្សេងទៀត**ភាគច្រើន** ដូចជា Schoolnet ការប្រឡង STAR របាយការណ៍ពិន្ទុ។ល។

ជាកិច្ចសំខាន់ក្នុងការកត់សម្គាល់ថាព័ត៌មានថ្មីៗទាំងនេះនឹងមិនបង្ហាញនៅក្នុងប្រព័ន្ធដែលគ្រប់គ្រង ដោយរដ្ឋទេ ហើយគ្មានអ្វីជំនួសឈ្មោះស្របច្បាប់របស់សិស្សបានទេ។ នៅពេលបញ្ជូនព័ត៌មានទៅ

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា ក្រសួងនឹងអាចកត់សម្គាល់ថាសិស្សកំណត់ថាប្រុសផង ស្រីផង ឬគ្មានភេទ ប៉ុន្តែរដ្ឋតម្រូវឱ្យកត់ត្រា និងបង្ហាញព័ត៌មានពីសំបុត្រកំណើតស្របច្បាប់។ យើងបន្តនូវការគាំទ្រសម្រាប់ការផ្លាស់ប្តូរដែលស្រដៀងៗគ្នាឱ្យអនុម័តនៅថ្នាក់រដ្ឋ និងរដ្ឋសហព័ន្ធ។

ប្រសិនបើលោកអ្នកមានសំណួរបន្ថែម សូមមើលគេហទំព័រ www.philasd.org/studentrights/lgbtqia/ ឬទាក់ទងតាមរយៈអ៊ីមែល policy252@philasd.org។

នេះគឺជាជំហានដ៏សំខាន់ឆ្ពោះទៅកាន់កិច្ចខិតខំប្រឹងប្រែងរបស់យើងឱ្យក្លាយទៅជាក្រសួងអប់រំដែលកាន់តែមានសមធម៌ និងការរួមបញ្ចូល។ អរគុណចំពោះការចូលរួមជាដៃគូរបស់លោកអ្នក នៅពេលដែលយើងខិតខំដើម្បីគាំទ្រដល់សុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងអារម្មណ៍របស់ក្មេងទាំងអស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

ដោយសេចក្តីស្មោះស្ម័គ្រ

William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា